

# ការពារខ្លួនអ្នកពីជំងឺ គ្រុនផ្តាសាយបក្សី នៅពេល ធ្វើការជាមួយបសុបក្សី ដែល មានមេរោគ

## ជំងឺផ្តាសាយបក្សីអាចឆ្លងពីបសុបក្សីទៅមនុស្ស និងធ្វើឱ្យអ្នកឈឺបាន។

- មេរោគអាចមាននៅក្នុងលាមក វត្ថុរាវ ឬរោមបក្សីឈឺ។
- វាអាចរីករាលដាលតាមរយៈបន្សាយទឹក ធូលី ឬដំណក់ទឹកក្នុងខ្យល់។ របស់ទាំងនេះអាចចូលភ្នែក ច្រមុះ មាត់ និង សួត។
- វាក៏អាចឆ្លងរាលដាលផងដែរ ប្រសិនបើអ្នកប៉ះផ្ទៃខាងក្រៅដែលមានមេរោគ រួចប៉ះមុខរបស់អ្នក។

## ការពារភ្នែក ច្រមុះ និងមាត់របស់អ្នក។

ពាក់ឧបករណ៍ការពារខ្លួន (PPE) ជានិច្ចនៅពេលធ្វើការជាមួយបក្សីដែលអាចឈឺ។



ពាក់វ៉ែនតាការពារភ្នែក (មានខ្យល់ចេញចូលដោយប្រយោល)។



ពាក់ឧបករណ៍ដកដង្ហើម N95 ឬឧបករណ៍ដែលមានប្រសិទ្ធភាពជាងនេះ។



ពាក់ស្រោមដៃ ហើយកុំប៉ះមុខរបស់អ្នក។



លាងដៃ ឬលាងសម្អាតដៃឱ្យបានញឹកញាប់អំឡុងពេលធ្វើការ។

បន្ថែមពីលើនេះ ពាក់ខោអាវការពាររាងកាយទាំងមូល ស្បែកជើងកវែង និងថង់គ្របការពារក្បាលឬសក់។



## ត្រូវការឧបករណ៍ការពារខ្លួន (PPE) បន្ថែមសម្រាប់កិច្ចការដែលមានហានិភ័យខ្ពស់។

ការងារមួយចំនួនអាចធ្វើឱ្យអ្នកប្រឈមនឹងមេរោគ ឬសារធាតុគីមីដែលបង្កគ្រោះថ្នាក់កាន់តែច្រើន ដូច្នេះទើបត្រូវការការការពារបន្ថែមទៀត។ ការងារទាំងនេះរួមមាន៖

- ការកម្ចាត់ចោលពពួកបក្សី
- ការផ្លាស់ទីនិងយកបក្សីដែលងាប់ធ្វើជីកំប៉ុស
- ការសម្អាត និងសម្លាប់មេរោគទ្រុងបក្សី
- ឬការងារផ្សេងទៀតនៅក្នុងអគារឬកន្លែងបិទជិត ដែលមេរោគអាចបង្កើនចំនួនច្រើនឡើង។

ក្នុងស្ថានភាពទាំងនេះ ឧបករណ៍ដកដង្ហើម N95 គឺមិនគ្រប់គ្រាន់ដើម្បីការពារសួតរបស់អ្នកទេ។ ម្យ៉ាងទៀត កុំភ្លេចរក្សាភ្នែករបស់ អ្នកឱ្យមានសុវត្ថិភាព។ ពាក់ឧបករណ៍ដកដង្ហើមណាមួយខាងក្រោម៖



ឧបករណ៍ដកដង្ហើមពាក់កណ្តាលមុខដែលឃឹតអាចបត់បែនបាន (ប្រភេទកៅស៊ូ) ជាមួយតម្រង P-100 និងវ៉ែនតាការពារភ្នែកមានខ្យល់ចេញចូលដោយប្រយោល។



ឧបករណ៍ដកដង្ហើមពេញមួយផ្ទៃមុខដែលឃឹតអាចបត់ បែនបាន (ប្រភេទកៅស៊ូ) ជាមួយតម្រង P-100



ឧបករណ៍ដកដង្ហើមបន្សុទ្ធខ្យល់ដើរដោយថាមពល (PAPR) ជាមួយនឹងតម្រងខ្យល់ភាគល្អិត (HEPA) មានប្រសិទ្ធភាពខ្ពស់

- ប្រសិនបើសារធាតុគីមីពាក់ព័ន្ធនឹងការងារទាំងនេះ សូមជ្រើសរើសតម្រងដែលត្រឹមត្រូវ។
- ខោអាវការពាររាងកាយទាំងមូលដែលធន់នឹងជាតិទឹក គួរពាក់នៅពេលសម្អាត និងសម្លាប់មេរោគទ្រុងបក្សី។
- ឧបករណ៍ការពារខ្លួន (PPE) ទាំងអស់គួរតែត្រូវបានផ្តល់ដោយនិយោជករបស់អ្នក ដោយមិនឥតគិតថ្លៃឡើយ។
- បន្ទាប់ពីបញ្ចប់វេនធ្វើការរបស់អ្នក សូមដោះឧបករណ៍ការពារ PPE ចេញ និងងូតទឹក។

## តាមដានខ្លួនអ្នកក្រែងលោមានរោគសញ្ញាជំងឺផ្តាសាយបក្សី។

ប្រសិនបើអ្នកមានរោគសញ្ញាដូចជំងឺគ្រុនផ្តាសាយ រួមមានក្រហមភ្នែក ឬមានហូរទឹកភ្នែក សូមទាក់ទងទៅនាយកដ្ឋានសុខភាពក្នុងតំបន់របស់អ្នក។ និយោជកត្រូវតែផ្តល់អត្ថប្រយោជន៍សំណងទូទាត់ដល់កម្មករ សម្រាប់កម្មករណាដែលកើតជំងឺផ្តាសាយបក្សីពេលបំពេញការងារ។ សម្រាប់ព័ត៌មានបន្ថែមអំពីសំណងទូទាត់ដល់កម្មករ និងច្បាប់ឈប់សម្រាកពេលមានជំងឺ សូមហៅទូរសព្ទទៅលេខ 1-800-736-7401។

## សម្រាប់ព័ត៌មានបន្ថែម៖

គេហទំព័រអំពីជំងឺផ្តាសាយបក្សីរបស់ CDPH៖ **go.cdph.ca.gov/birdflu**
ខ្សែទូរសព្ទជំនួយគ្រោះថ្នាក់នៅកន្លែងការងារនៃសេវាប្រព័ន្ធវាយតម្លៃគ្រោះថ្នាក់ និងសេវាព័ត៌មាន៖ (866) 282-5516
ខ្សែទូរសព្ទជំនួយសម្រាប់ព័ត៌មានសុខភាព នៃមជ្ឈមណ្ឌលជាតិសម្រាប់សុខភាពកម្មករក្នុងកសិដ្ឋាន៖ +1 (800) 377-9968 ឬតាម WhatsApp តាមរយៈលេខ + 1 (737) 999-4162

ខែឧសភា ២០២៥ © ២០២៥, នាយកដ្ឋានសុខភាពសាធារណៈរដ្ឋកាលីហ្វ័រញ៉ា